# CCHR រកឃើញថាអ្នកហ៊ានបញ្ចេញមតិរិះគន់រដ្ឋាភិបាលនៅតែត្រូវបានកំណត់ជាមុខសញ្ញាក្នុងការបំភិតបំភ័យ




មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អះអាងថា ការបំភិតបំភ័យ ការគំរាមកំហែងពីសំណាក់រដ្ឋាភិបាល និងការឃាំឃីតាមប្រព័ន្ធតុលាការ គឺជាវិធានការដែលត្រូវប្រើប្រាស់សម្រាប់កំណត់មុខសញ្ញាអ្នកហ៊ានបញ្ចេញមតិ ឬអ្នកហ៊ានរិះគន់រដ្ឋាភិបាល។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) បានចេញផ្សាយរបាយការណ៍របស់ខ្លួនកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤ ថា សិទ្ធិសេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មាននៅតែបន្តវាយប្រហារនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីដើមខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ចុងខែសីហា ឆ្នាំ២០២៤ កន្លងទៅនេះ។

CCHR ថាអ្នកសារព័ត៌មាននៅកម្ពុជា ជាពិសេសអ្នកដែលដើរតួនាទីឃ្លាំមើល និងជាអ្នករាយការណ៍ព័ត៌មានសម្ងាត់ ជារឿយៗតែងប្រឈមនឹងការគំរាមកំហែងដល់សុវត្ថិភាពរូបរាងកាយ ក្នុងនោះក៏មានការគំរាមកំហែងដល់អាយុជីវិតផងដែរ។

ប្រភពដដែលលើកឡើងថា អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស នៅតែបន្តប្រឈមនឹងសម្ពាធពីរាជរដ្ឋាភិបាលកម្ពុជា រួមទាំងការឃាំឃីតាមប្រព័ន្ធតុលាការ ដែលសម្ពាធនេះបានរារាំងដល់សមត្ថភាពរបស់ពលរដ្ឋក្នុងការសម្តែងមតិអំពីការមិនពេញចិត្ត ឬការលើកឡើងអំពីក្តីបារម្ភពាក់ព័ន្ធនឹងបញ្ហារសើបនានា។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាត្រូវតែបញ្ឈប់ការដៅមុខសញ្ញាលើសំឡេងរិះគន់ជាបន្ទាន់ ដោយធានាឱ្យបាននូវការទទួលខុសត្រូវពីបទរំលោភបំពាន និងបណ្ដុះនូវបរិយាកាសដែលពលរដ្ឋអាចអនុវត្តសិទ្ធិរបស់ពួកគេដោយគ្មានការភ័យខ្លាច។ ផ្ទុយទៅវិញ បើរដ្ឋាភិបាលមិនអាចអនុវត្តបែបនេះបានទេ នោះប្រជាធិបតេយ្យនឹងនៅតែបន្តធ្លាក់ចុះ ហើយកម្ពុជានឹងត្រូវឃ្លាតឆ្ងាយពីសហគមន៍អន្តរជាតិកាន់តែខ្លាំងជាងនេះបន្ថែមទៀត។

ចាប់តាំងពីដើមខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ចុងខែសីហា ឆ្នាំ២០២៤ ត្រូវបានគេរកឃើញថាស្ថានភាពសេរីភាពសារព័ត៌មានស្ថិតក្នុងការរឹតត្បិតធ្ងន់ធ្ងរ ក្នុងនោះ អាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយយ៉ាងតិចចំនួន ៣ ត្រូវបានដកហូត ខណៈអ្នកសារព័ត៌មានជិត ២០នាក់ (១៧នាក់) ត្រូវប្រឈមមុខនឹងផ្លូវច្បាប់។

យ៉ាងណាក៏ដោយ កាលពីចុងខែមេសា ឆ្នាំ២០២៤ ក្រសួងព័ត៌មាន បានចេញផ្សាយរបាយការណ៍ស្តីពីស្ថានភាពនៃសេរីភាពសារព័ត៌មាននៅកម្ពុជាដោយផ្អែកលើការស្ទង់មតិអ្នកសារព័ត៌មានជាង ៣០០នាក់ (៣៤១នាក់) នៅទូទាំងប្រទេស ដោយបង្ហាញថា ៧៩,៨% បានវាយតម្លៃថាសេរីភាពសារព័ត៌មាននៅកម្ពុជាល្អ ឬល្អណាស់។

ទោះជាបែបនេះក្តី អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF) បានចេញផ្សាយពីសន្ទស្សន៍សេរីភាពសារព័ត៌មានសម្រាប់ឆ្នាំ២០២៤ កាលពីដើមខែសីហា ឆ្នាំ២០២៤ នេះថា កម្ពុជាធ្លាក់ចំណាត់ថ្នាក់ខាងសេរីភាពសារព័ត៌មានចំនួន ៩លេខសម្រាប់ឆ្នាំ២០២៤ នេះ គឺធ្លាក់ពីលេខ១៤២ ក្នុងឆ្នាំ២០២២ មកចំណាត់ថ្នាក់លេខ១៥១ ដោយសារតែគេរកឃើញថា រដ្ឋាភិបាលកម្ពុជាបានវាយប្រហារ និងគាបសង្កត់លើសេរីភាពសារព័ត៌មានឯករាជ្យកាន់តែធ្ងន់ធ្ងរ៕